## អ្វីដែលបុរសស្រឡាញ់ភេទដូចគ្នា និងបុរសស្រឡាញ់ភេទទាំងពីរ

# ត្រូវដឹងអំពីជំងឺអុតស្វា

ករណីឆ្លងមួយចំនួនត្រូវបានរកឃើញក្នុងចំណោមបុរសស្រឡាញ់ភេទដូចគ្នា និងបុរសស្រឡាញ់ភេទទាំងពីរ **ប៉ុន្តែមិនមែនទាំងអស់នោះទេ**

## អ្វីទៅជាជំងឺអុតស្វា?

ជំងឺអុតស្វាគឺជាជំងឺដែលបង្កពីមេរោគដែលអាចចម្លងបានដោយការប៉ះពាល់ជិតស្និទ្ធដូចជាការថើប ឬការរួមភេទ ហើយនិងការប៉ះពាល់ស្បែកនិងស្បែកផ្សេងទៀត។ អត្រាការស្លាប់ក្នុងអំឡុងពេលនៃការផ្ទុះឡើងនៃជំងឺនេះនាពេលបច្ចុប្បន្ននេះ ត្រូវបានរំពឹងថាមានកម្រិតទាប។

## ជំងឺនេះមានរោគសញ្ញាអ្វីខ្លះ?

### រោគសញ្ញាសំខាន់

**កន្ទួលរមាស់ ដុំពក ឬពងបែក**

ទាំងនេះអាចលេចចេញនៅកន្លែងណាក៏ដោយនៅលើខ្លួនប្រាណ រួមទាំងប្រដាប់ភេទផងដែរ។ វាអាចមើលទៅស្រដៀងនឹង ពោគរើម ឬរោគស្វាយ ឬក៏កន្ទួលរមាស់លើស្បែកទូទៅផ្សេងទៀត។

### រោគសញ្ញាផ្សេងទៀត

- គ្រុនក្តៅ និង ឈឺក្បាល
- ឈឺសាច់ដុំ
- ហើមកូនកណ្តុរ

រោគសញ្ញាចាប់ផ្តើមកើតមានចន្លោះពី 5 ទៅ 21 ថ្ងៃ

## អ្វីដែលអ្នកអាចធ្វើបាន

### តាមដានសេចក្តីជូនដំណឹង

រក្សាភាពស្ងប់ស្ងាត់។ នេះគឺជាស្ថានភាពមួយដែលមានការប្រែប្រួលយ៉ាងឆាប់រហ័ស។ សូមចូលទៅកាន់គេហទំព័ររបស់ CDC សម្រាប់សេចក្តីណែនាំដែលទាន់ហេតុការណ៍។

### ទំនាក់ទំនង

ប្រសិនបើអ្នកមានរោគសញ្ញានានា សូមទូរស័ព្ទ (មិនមែនទៅដោយផ្ទាល់ទេ) ទៅអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នក ហើយសួរអំពីការធ្វើតេស្ត។

### ដាក់ខ្លួននៅដាច់ដោយឡែក

ប្រសិនបើអ្នកមានរោគសញ្ញានានា សូមនៅតែផ្ទះ ពាក់មាស់ និងរុំដំបៅឲ្យបានជិតល្អ ដើម្បីការពារអ្នកដទៃ។

បានធ្វើបច្ចុប្បន្នកម្មៈ ខែមិថុនា ឆ្នាំ 2022

**បញ្ឈប់ការរើសអើង**

## នរណាម្នាក់ក៏អាចកើតជំងឺអុតស្វាដែរ

ការស្តីបន្ទោសទៅលើបុរសដែលស្រឡាញ់ភេទដូចគ្នា ឬបុរសដែលស្រឡាញ់ភេទទាំងពីរ ឬក៏បុរសដទៃទៀតដែលរួមភេទជាមួយបុរសដូចគ្នានោះ អាចនឹងបណ្តាលឲ្យខាតបង់ដល់កិច្ចខំប្រឹងប្រែងផ្នែកសុខភាពសាធារណៈ ហើយនិងធ្វើឲ្យអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពខកខានការប្រឆាំងនឹងជំងឺអុតស្វានៅក្នុងសហគមន៍ដទៃទៀត។

ទទួលបានព័ត៌មានថ្មីបំផុត និងទាញយកឯកសារពី
**Gay Sexuality & Social Policy Initiative @ UCLA Luskin**
gaysexresearch.com

California Department of Public Health
County of Los Angeles Public Health
GSSPI gaysexresearch.com
Los Angeles LGBT Center